Statement of the Ministry of National Defense on 23 April 2011



Kingdom of Cambodia
Nation Religion King

Ministry of National Defense

Statement of the Ministry of National Defense

Following its military aggression yesterday, the Thai armed forces once again resumed its offensive against Cambodia today, at 06:15 in the area of Tamone Temple, and at 06:45 in the area of Ta Krabei Temple. The apparent goal of Thailand's attacks against Cambodia is to take control over these temples of Cambodia.

Today's assault by Thai infantry units is supported by Thai military aircrafts, including reconnaissance planes, which flew deep into Cambodia's airspace. Heavy weapons, including 130mm 105mm and 155mm artilleries, have also been used during this latest military onslaught.

This is the third offensive since yesterday and constituted the fifth series of military aggression by Thai armed forces against Cambodia, since 2008. During the last aggression against Cambodia from 4 to 7 February this year, the Thai armed forces used cluster munitions which claimed many Cambodian casualties. In today's assault, the Thai side has used DK 75 and 105mm heavy guns loaded with poisonous gas.

The Ministry of National Defense of Cambodia condemns in the strongest term these repeated deliberate acts of aggression by Thailand against Cambodia. The Ministry of National Defense, on behalf of the Royal Government of Cambodia, earnestly calls on the Thai side to permanently cease its military hostilities against Cambodia, in order to allow a peaceful settlement of the border problems between the two counties.

Phnom Penh, 23 April 2011

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សេចក្តីថ្លែងការណ៍របស់ក្រសួងការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា

បន្ទាប់ពីការឈ្លានពានដោយយោធាកាលពីម្សិលមិញ កងកម្លាំងប្រដាប់អាវុធថៃបានចាប់ផ្តើមធ្វើការវាយលុកជាថ្មីម្តងទៀតមកលើប្រទេសកម្ពុជានៅថ្ងៃនេះ វេលាម៉ោង ០៦:១៥ នៅតំបន់ប្រាសាទ **តាមាន់** និង វេលាម៉ោង ០៦:៤៥ នៅតំបន់ប្រាសាទ **តាក្របី** ។ គោលដៅពិតនៃការវាយប្រហាររបស់ថៃ មកលើកម្ពុជា គឺដើម្បីដណ្តើមកាន់កាប់ប្រាសាទរបស់កម្ពុជាទាំងនេះ ។

ការវាយប្រហារដោយអង្គភាពកងទ័ពថ្មើរជើងថៃ មានការគាំទ្រផងដែរពីយន្តហោះយោធាថៃ ដែលរួមមានទាំងយន្តហោះឈ្លបការណ៍ផង ដែលបានហោះហើរចូលជ្រៅមកក្នុងដែនអាកាសកម្ពុជា។ អាវុធធុនធ្ងន់ រួមទាំងកាំភ្លើងធំ ១៣០ មម ១០៥មម និង ១៥៥ មម ក៏ត្រូវបានគេប្រើប្រាស់ផងដែរក្នុងការវាយប្រហារនេះ។

ការវាយលុកម្តងលើកឡើង គឺជាលើកទី ៣ ហើយ គិតចាប់តាំងពីថ្ងៃម្សិលមិញ និងជាការវាយប្រហារឈុតទី ៥ គិតពីឆ្នាំ ២០០៨ មក។ នៅក្នុងការឈ្លានពានពីថ្ងៃទី ៤ ដល់ថ្ងៃទី ៧ កុម្ភៈ ឆ្នាំនេះ កម្លាំងប្រដាប់អាវុធថៃបានប្រើគ្រាប់បែកចង្កោម ដែលបានធ្វើឱ្យខូចខាតដល់អាយុជីវិតប្រជាជនកម្ពុជាជាច្រើននាក់។ ក្នុងការវាយប្រហារនៅថ្ងៃនេះ ភាគីថៃបានប្រើកាំភ្លើងធុនធ្ងន់ ដេកា ៧៥ និង ១០៥ មម ដែលមានផ្ទុកទាំងឧស្ម័នពុលផង។

ក្រសួងការពារជាតិកម្ពុជាថ្កោលទោសយ៉ាងធ្ងន់ធ្ងរបំផុតចំពោះការឈ្លានពានដោយចេតនាម្តងហើយម្តងទៀត ដោយប្រទេសថៃ មកលើប្រទេសកម្ពុជា។ ក្រសួងការពារជាតិ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា សូមអំពាវនាវយ៉ាងទទូចដល់ភាគីថៃ សូមឱ្យបញ្ឈប់ជាអចិន្ត្រៃយ៍នូវអំពើប្រទូស្តរ៉ាយដោយយោធាប្រឆាំងនឹងកម្ពុជា ដើម្បីទុកលទ្ធភាពឱ្យមានដំណោះស្រាយដោយសន្តិវិធីចំពោះបញ្ហាព្រំដែនរវាងប្រទេសទាំងពីរ។

ភ្នំពេញ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១១

ទីស្តីការក្រសួងការពារជាតិ ទូរស័ព្ទ-ទូរសារ : (៨៥៥) ០២៣ ៨៨៣២៧៤ E.Mail : Minadef@camnet.com.kh